# ស្ទង់មតឆ្នាំ២០២៣៖ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីពទទួលបានច្រើនល្ងងសេរីភាពជាមូលដ្ឋាន

អង្គការសិទ្ធិមនុស្សចំនួន ៣ គឺមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា សមាគមអាដហុក និង SOLIDARITY CENTERបានធ្វើការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីពរយៈពេល ៨ឆ្នាំពីឆ្នាំ ២០១៦ ដល់ឆ្នាំ ២០២៣។ បើនិយាយតែក្នុងឆ្នាំ ២០២៣ មួយ ការស្ទង់មតិបានធ្វើលើថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីពចំនួន១៥៩នាក់ ដែលតំណាងឲ្យអង្គការសង្គមស៊ីវិល១០៤នាក់ និងសហជីពចំនួន៥៥ នាក់នៅកម្ពុជា។ លទ្ធផលបានបង្ហាញពីការវិវឌ្ឍន៍វិជ្ជមានស្តីពីសេរីភាពជាមូលដ្ឋានដែលថ្នាក់ដឹកនាំសង្គមស៊ីវិល និងសហជីពទទួលបាន។

នៅក្នុងឆ្នាំ២០២៣ ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីពបានយល់ឃើញថា ការតាមឃ្លាំមើលហួសហេតុរបស់រដ្ឋាភិបាលបានថយចុះចំនួន ៦ភាគរយ ពោលពី៦៤ភាគរយក្នុងឆ្នាំ២០២២ មកនៅ៥៨ ភាគរយក្នុងឆ្នាំ២០២៣។ សម្រាប់ក្រុមអ្នកចងក្រងរបាយការណ៍ នេះជាការវិវឌ្ឍវិជ្ជមានមួយក្នុងឆ្នាំ ២០២៣ គិតតាំងពីឆ្នាំ២០១៦។

ទន្ទឹមគ្នានេះ ៥៤ភាគរយនៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីពទាំងជាង១៥០នាក់ក៏បានមើលឃើញថា ការទទួលស្គាល់ពួកគេជាដៃគូអភិវឌ្ឍន៍ស្របច្បាប់ពីសំណាក់រដ្ឋាភិបាលបានកើនឡើងចំនួន ៣ ភាគរយក្នុងឆ្នាំ ២០២៣ ធៀបនឹងឆ្នាំ ២០២២។

ចំណុចវិជ្ជមានមួយទៀតដែលលើកឡើងដោយថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីពភាគច្រើន គឺការថយចុះចំនួន ១៦ភាគរយនៃអារម្មណ៍ពុំមានសុវត្ថិភាពក្នុងការបញ្ចេញមតិយោបល់តាមប្រព័ន្ធផ្សព្វផ្សាយ។ តែអ្នកចងក្រងរបាយការណ៍មានការភ្ញាក់ផ្អើលចំពោះភាគរយនេះ ដែលគេយល់ថា ជាភាគរយតិចបំផុតចាប់តាំងពីការចាប់ផ្តើមកត់ត្រារបស់គម្រោងក្នុងឆ្នាំ២០១៦។

ទន្ទឹមនឹងការវិវឌ្ឍន៍ជាវិជ្ជមាន អង្គការសង្គមស៊ីវិលនៅតែត្រូវបានផាត់ចេញពីការជជែកពិភាក្សានៅក្នុងការតាក់តែងច្បាប់ ដូចជាការធ្វើវិសោធនកម្មច្បាប់បោះឆ្នោតដែលបានអនុម័តក្នុងខែកក្កដាឆ្នាំ២០២៣ ដោយគ្មានការពិភាក្សា។

គួរបញ្ជាក់ថា គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋានស្ថិតក្រោមការគ្រប់គ្រងរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា សមាគមអាដហុក និងSOLIDARITY CENTER៕